សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង

## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាអេស្ប៉ាញ និងភាសាដទៃទៀត។ សូមចូលទៅwww.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ការចាក់ថ្នាំវ៉ាក់សាំងនេះអាចការពារមនុស្សពី**មេរោគបង្កជំងឺស្វិតដៃជើង**។ ជំងឺស្វិតដៃជើង គឺជាជំងឺ ដែលបង្កឡើងដោយមេរោគ។ មេរោគចម្លងជាចម្បង តាមរយៈការប៉ះពាល់គ្នារវាងមនុស្សម្នាក់ នឹងមនុស្សម្នាក់ទៀត។ មេរោគនេះក៏អាចចម្លងតាមរយៈការបរិភោគអាហារ ឬទឹក ឬភេសជ្ជៈ ដែលកង្វក់ដោយសារលាមករបស់អ្នកឆ្លងមេរោគនេះផងដែរ។

មនុស្សភាគច្រើន ដែលឆ្លងមេរោគជំងឺស្វិតដៃជើង ពុំមានរោគសញ្ញាទេ ហើយមនុស្សជាច្រើននាក់ជាសះស្បើយឡើងវិញដោយគ្មានកើតរោគផ្សេងឡើយ។ ប៉ុន្តែ ពេលខ្លះ មនុស្ស ដែលឆ្លងមេរោគជំងឺស្វិតដៃជើង កើតរោគខ្វិន (មិនអាចធ្វើចលនាដៃ ឬជើងរបស់ពួកគេបាន) មេរោគជំងឺស្វិតដៃជើងអាចបង្ករោគពិការអចិន្ត្រៃយ៍។ មេរោគជំងឺស្វិតដៃជើង ក៏អាចបណ្តាលឲ្យស្លាប់បាត់បង់ជីវិតផងដែរ ដែលជាធម្មតាដោយធ្វើឲ្យខ្វិនសាច់ដុំដែលប្រើសម្រាប់ដកដង្ហើម។

ជំងឺស្វិតដៃជើង ធ្លាប់ជាមេរោគសាមញ្ញណាស់ នៅសហរដ្ឋអាមេរិក។ មេរោគនេះបានធ្វើឲ្យមនុស្សរាប់ពាន់នាក់ខ្វិន ឬស្លាប់បាត់បង់ជីវិតរៀងរាល់ឆ្នាំ មុនពេលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង ត្រូវបានដាក់ឲ្យប្រើប្រាស់នៅឆ្នាំ 1955។ ពុំមានវិធីព្យាបាលការឆ្លងមេរោគជំងឺស្វិតដៃជើងទេ ប៉ុន្តែ មេរោគនេះអាចបង្ការបាន តាមរយៈថ្នាំវ៉ាក់សាំង។

ជំងឺស្វិតដៃជើងត្រូវបានលុបបំបាត់ពីសហរដ្ឋអាមេរិក។ ប៉ុន្តែជំងឺនេះនៅតែកើតឡើងនៅតំបន់ដទៃទៀតលើពិភពលោក។ មនុស្សតែម្នាក់ដែលឆ្លងមេរោគជំងឺស្វិតដៃជើងមកពីប្រទេសដទៃ អាចនាំជំងឺនេះមកសហរដ្ឋអាមេរិកវិញបាន ប្រសិនបើយើងពុំត្រូវបានការពារដោយថ្នាំវ៉ាក់សាំងទេនោះ។ ប្រសិនបើកិច្ចប្រឹងប្រែងលុបបំបាត់ជំងឺនេះពីលើពិភពលោកទទួលបានជោគជ័យ នៅថ្ងៃអនាគត យើងនឹងមិនត្រូវការថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងឡើយ។ ប៉ុន្តែមុនដល់ពេលនោះ យើងចាំបាច់ត្រូវឲ្យកូនៗរបស់យើងទទួលថ្នាំវ៉ាក់សាំងនេះ។

## 2 ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង

ថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើង ដែលមិនសកម្ម(**IPV**) អាចបង្ការជំងឺស្វិតដៃជើងបាន។

**កុមារ**
មនុស្សភាគច្រើនគួរទទួលថ្នាំវ៉ាក់សាំង IPV នៅពេលពួកគេនៅជាកុមារ។ ជាធម្មតា ដូសថ្នាំវ៉ាក់សាំងត្រូវបានផ្តល់ឲ្យនៅអាយុ 2, 4, 6 ទៅ 18 ខែ និង 4 ទៅ 6 ឆ្នាំ។

កាលវិភាគនេះអាចខុសៗគ្នា ចំពោះកុមារមួយចំនួន (រាប់ទាំងកុមារដែលធ្វើដំណើរទៅប្រទេសជាក់លាក់ និងកុមារ ដែលទទួលថ្នាំវ៉ាក់សាំង IPV ក្នុងថ្នាំវ៉ាក់សាំងរួមផ្សំ)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកបាន។

**មនុស្សពេញវ័យ**
មនុស្សពេញវ័យភាគច្រើន មិនត្រូវការថ្នាំវ៉ាក់សាំង IPV ទេ ព្រោះពួកគេបានទទួលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងរួចហើយ ពេលនៅជាកុមារ។ ប៉ុន្តែ មនុស្សពេញវ័យមួយចំនួន មានហានិភ័យខ្ពស់ ហើយគួរពិចារណាទទួលថ្នាំវ៉ាក់សាំងជំងឺស្វិតដៃជើងនេះ ក្នុងនោះ រួមបញ្ចូល៖

- មនុស្សដែលធ្វើដំណើរទៅកាន់តំបន់ណាមួយនៅលើពិភពលោក
- បុគ្គលិកនៃមន្ទីរពិសោធន៍ ដែលប្រហែលធ្វើពិសោធន៍លើមេរោគជំងឺស្វិតដៃជើង និង
- បុគ្គលិកថែទាំសុខភាព ដែលព្យាបាលអ្នកជំងឺ ដែលអាចមានមេរោគជំងឺស្វិតដៃជើង។

មនុស្សពេញវ័យ ដែលមានហានិភ័យខ្ពស់ទាំងនេះ អាចត្រូវការថ្នាំវ៉ាក់សាំង IPV ពី 1 ទៅ 3 ដូស ផ្អែកលើចំនួនដូស ដែលពួកគេធ្លាប់ទទួលរួចហើយកន្លងមក។

គេពុំដឹងពីហានិភ័យចំពោះការទទួលថ្នាំវ៉ាក់សាំង IPV ក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀតឡើយ។

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាក់វ៉ាក់សាំងនេះ។

សូមប្រាប់អ្នកដែលផ្តល់ថ្នាំវ៉ាក់សាំងដល់លោកអ្នក៖

- **ប្រសិនបើបុគ្គល ដែលទទួលថ្នាំវ៉ាក់សាំង មានបញ្ហាអាឡែក់ស៊ីធ្ងន់ធ្ងរ ដែលគំរាមកំហែងដល់អាយុជីវិត។**
  ប្រសិនបើលោកអ្នកធ្លាប់មានប្រតិកម្មអាឡែក់ស៊ីដែលគំរាមកំហែងដល់អាយុជីវិត បន្ទាប់ពីបានទទួលដូសថ្នាំវ៉ាក់សាំង IPVឬមានបញ្ហាអាឡែក់ស៊ីធ្ងន់ធ្ងរចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំងនេះ លោកអ្នកអាចត្រូវបានណែនាំកុំឲ្យទទួលថ្នាំវ៉ាក់សាំងនេះ។ សូមសួរនាំអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកចង់បានព័ត៌មានអំពីធាតុផ្សំនៃថ្នាំវ៉ាក់សាំង។

- **ប្រសិនបើបុគ្គល ដែលទទួលថ្នាំវ៉ាក់សាំង មានសុខភាពមិនស្រួលទេ។**
  ប្រសិនបើលោកអ្នកមានជំងឺឈឺស្រាល ដូចជា ជំងឺផ្តាសាយ លោកអ្នកប្រហែលអាចទទួលបានថ្នាំវ៉ាក់សាំងនៅថ្ងៃនេះ។ ប្រសិនបើលោកអ្នកមានជំងឺឈឺមធ្យម ឬធ្ងន់ធ្ងរ លោកអ្នកគួរប្រហែលរង់ចាំ រហូតទាល់តែលោកអ្នកជាសះស្បើយវិញ។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់យោបល់លោកអ្នក។

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលរំខាន អាចកើតមាន។ ជាធម្មតា ផលរំខានទាំងនេះមានកម្រិតស្រាល ហើយបាត់ទៅវិញដោយខ្លួនឯង ប៉ុន្តែប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

មនុស្សមួយចំនួន ដែលទទួលថ្នាំវ៉ាក់សាំង IPV អាចឈឺចាប់នៅកន្លែងចាក់ថ្នាំ។ ពុំមានព័ត៌មានបង្ហាញថា ថ្នាំវ៉ាក់សាំង IPV បង្កបញ្ហាធ្ងន់ធ្ងរឡើយ ហើយមនុស្សភាគច្រើនពុំមានបញ្ហាជាមួយនឹងថ្នាំវ៉ាក់សាំងនេះទេ។

**បញ្ហាដទៃទៀតដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងណាក៏ដោយ៖**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេក ប្រហែល 15 នាទីបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួលបាន។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនឈឺស្មារ ដែលអាចកាន់តែធ្ងន់ធ្ងរ និងកើតឡើងសម្រាប់រយៈពេលយូរ ជាការឈឺចាប់ធម្មតាក្រោយពេលចាប់ថ្នាំ។ ករណីនេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើង ក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖
**www.cdc.gov/vaccinesafety/**

## 5 ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

  សញ្ញាបង្ហាញពី**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** អាចរួមបញ្ចូលកន្ទួរហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជា**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនដូច្នោះទេ សូមទូរស័ព្ទទៅគ្លីនិករបស់លោកអ្នក។

  ក្រោយមក ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំ)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ**www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក**1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (VICP) (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅវេបសាយ VICP នៅ **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមទាក់ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ)៖
  - ដោយហៅទូរស័ព្ទទៅលេខ **1-800-232-4636** (**1-800-CDC-INFO**) ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

Vaccine Information Statement
# Polio Vaccine

7/20/2016

Khmer

42 U.S.C. § 300aa-26

Office Use Only

Translation provided by the Immunization Action Coalition